**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**
**លេខ** : ១១៧/២៥ ក.ប/ប្រក.អ.ភ.ក

# ប្រកាស
# ស្ដីពី
# ការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងការព្យួរការឈប់សម្រាកប្រចាំសប្ដាហ៍

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤ នៃច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្ដីពីការងារ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៨៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- យោងសេចក្តីជូនដំណឹងលេខ ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីលទ្ធផលនៃវេទិកាពរាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងការព្យួរការឈប់សម្រាកប្រចាំសប្តាហ៍។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាស គ្រឹះស្ថាន និងជនទាំងឡាយ ដែលស្ថិតនៅក្រោមដែនអនុវត្តនៃច្បាប់ស្តីពីការងារ។

## ជំពូកទី២
## ការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា

**ប្រការ៣ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានអាចរៀបចំឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងលើសពីថិរវេលាធ្វើការធម្មតារបស់សហគ្រាស គ្រឹះស្ថានរបស់ខ្លួន នៅក្នុងករណីដូចខាងក្រោម៖

- ដើម្បីឱ្យការងារពិសេសប្រព្រឹត្តទៅបាន ដូចជា ការធ្វើបញ្ជីសារពើភណ្ឌ និងតុល្យការ ការដាក់កំណត់ពេលវេលាការជម្រះបញ្ជី និងការបិទបញ្ជីគណនេយ្យ
- ដើម្បីឱ្យសហគ្រាស គ្រឹះស្ថានអាចទប់ទល់នឹងការងារ ដែលមានច្រើនខុសធម្មតាបណ្តាលមកពីកាលៈទេសៈប្លែកៗ ដោយមិនអាចរង់ចាំនិយោជកករកវិធានការដទៃផ្សេងទៀត។

**ប្រការ៤ .-**

ការរៀបចំធ្វើការបន្ថែមម៉ោងនេះ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានមិនត្រូវបង្ខិតបង្ខំ ឬដាក់វិន័យផ្សេងៗចំពោះកម្មករនិយោជិត ដែលមិនស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងឡើយ។

**ប្រការ៥ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតតាមអត្រាដូចខាងក្រោម៖

- ស្មើនឹង ១៥០ % (មួយរយហាសិបភាគរយ) ឬមួយដងកន្លះ នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលថ្ងៃ នៃថ្ងៃធ្វើការធម្មតា
- ស្មើនឹង ២០០% (ពីររយភាគរយ) ឬពីរដង នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលយប់ ចាប់ពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺ។

**ប្រការ៦ .-**

ចំពោះសហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតធ្វើការពេលយប់ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់ទីកន្លែងសម្រាកទទួលទានដំណេកឱ្យបានសមរម្យដល់កម្មករនិយោជិត ដែលចេញពីធ្វើការនៅពេលយប់ ឬត្រូវផ្តល់មធ្យោបាយសម្រាប់ដឹកជញ្ជូនកម្មករនិយោជិតទៅដល់លំនៅឋានរៀងៗខ្លួនវិញប្រកបដោយសុវត្ថិភាព នៅពេលចប់ម៉ោងធ្វើការពេលយប់។

## ជំពូកទី៣
## ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល

**ប្រការ៧ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតរបស់ខ្លួនបានឈប់សម្រាកដោយមានប្រាក់ឈ្នួលក្នុងឱកាសថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ដូចមានកំណត់ជារៀងរាល់ឆ្នាំដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៨ .-**

សហគ្រាស គ្រឹះស្ថាន ដែលមិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងករណីចាំបាច់ នាឱកាសថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានអាចសម្របសម្រួលជាមួយនឹងកម្មករនិយោជិតរបស់ខ្លួនឱ្យធ្វើការនៅថ្ងៃឈប់បុណ្យទាំងនេះបាន។

ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ត្រូវមានការស្ម័គ្រចិត្តពីកម្មករនិយោជិត។

**ប្រការ៩ .-**

កម្មករនិយោជិតដែលធ្វើការថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល មានសិទ្ធិទទួលនូវប្រាក់បំណាច់មួយដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។

## ជំពូកទី៤
## ការព្យួរការឈប់សម្រាកប្រចាំសប្តាហ៍

**ប្រការ១០ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចព្យួរការឈប់សម្រាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតបានក្នុងករណីដូចមានចែងក្នុងមាត្រា១៥១ នៃច្បាប់ស្តីពីការងារ។

**ប្រការ១១ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានប្រភេទខ្លះ អាចកាត់បន្ថយការឈប់សម្រាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតចំនួន ២ (ពីរ) ថ្ងៃ ក្នុង ១ (មួយ) ខែ ដើម្បីទូទាត់ថ្ងៃធ្វើការមិនកើតកន្លងទៅ ដែលបណ្តាលមកពីកត្តាអាកាសធាតុមិនល្អ។ ប្រភេទសហគ្រាស គ្រឹះស្ថានទាំងនោះរួមមាន៖

- សហគ្រាស គ្រឹះស្ថានបម្រើការងារសាធារណៈ ដូចជា ការងារបោសសម្អាត ឬប្រមូលសំរាមនៅតាមថ្នល់ ទីលានសាធារណៈ ការងារជួសជុល ធ្វើថ្នល់ ឬលូទឹក
- សហគ្រាស គ្រឹះស្ថានបម្រើការងារជួសជុល ឬតបំពង់ទឹក ឬបំពង់ឧស្ម័ន ជួសជុល ឬប្រក់ដំបូលផ្ទះ ឬអគារ
- សហគ្រាស គ្រឹះស្ថានសំណង់ចំពោះការងារដែលប្រព្រឹត្តទៅនៅផ្នែកខាងក្រៅនៃអគារ

- សហគ្រាស គ្រឹះស្ថានឡជង្ហចំពោះការងារដែលប្រព្រឹត្តទៅនៅកណ្តាលវាល
- សហគ្រាស គ្រឹះស្ថានកាយយករ៉ែចំពោះការងារដែលប្រព្រឹត្តទៅនៅកណ្តាលវាល
- សហគ្រាស គ្រឹះស្ថានដឹកជញ្ជូនតាមផ្លូវទឹក
- ភោជនីយដ្ឋាន និងកន្លែងលក់ដូរដែលប្រព្រឹត្តទៅនៅកណ្តាលវាល
- សហគ្រាស គ្រឹះស្ថានបេះ ឬប្រមូលផ្លែឈើ ឬបន្លែ
- សហគ្រាស គ្រឹះស្ថានចិញ្ចឹមសត្វសន្តានខ្យង ខ្ចៅ ឬត្រី
- សហគ្រាស គ្រឹះស្ថានផលិតទឹកត្រី ឬអំបិល
- សហគ្រាស គ្រឹះស្ថានធ្វើប្រកកំប៉ុងនូវផ្លែឈើ បន្លែ ឬត្រី
- សហគ្រាស គ្រឹះស្ថានលើកដាក់ផលិតផល ឬវត្ថុធាតុដែលឆាប់ខូច
- សហគ្រាស គ្រឹះស្ថានកសិកម្ម និងនេសាទ។

ការធ្វើការសងនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ចំពោះប្រភេទសហគ្រាស គ្រឹះស្ថានដូចបានរៀបរាប់ខាងលើ ត្រូវអនុវត្តក្នុងខែបន្ទាប់ពីថ្ងៃធ្វើការមិនកើតដោយអាកាសធាតុមិនល្អ។ ករណីត្រូវធ្វើការសងចំនួន ២ (ពីរ) ថ្ងៃ ថ្ងៃទាំងពីរនេះ មិនត្រូវជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ពីរដែលជាប់គ្នាឡើយ។

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវរៀបចំបែបបទនៃការឈប់សម្រាកសងដោយទូទាត់វិញ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។

**ប្រការ១២ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានអាចព្យួរការឈប់សម្រាកប្រចាំសប្តាហ៍របស់កម្មករនិយោជិត ដែលការព្យួរចំនួន ២ (ពីរ) ថ្ងៃ ក្នុង ១ (មួយ) ខែ មិនត្រូវជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ពីរដែលជាប់គ្នាឡើយ។

**ប្រការ១៣ .-**

កម្មករនិយោជិត ដែលធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ត្រូវបានប្រាក់ឈ្នួលស្មើនឹង ២ (ពីរ) ដងនៃប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។

## ជំពូកទី៥
## បែបបទ និងនីតិវិធីក្នុងការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងការព្យួរការឈប់សម្រាកប្រចាំសប្តាហ៍

**ប្រការ១៤ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវបំពេញទិន្នន័យពាក់ព័ន្ធនឹងការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងការព្យួរការឈប់សម្រាកប្រចាំសប្តាហ៍ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារតាមរយៈគេហទំព័រ https://lacms.mlvt.gov.kh យ៉ាងតិច ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទនៃការចាប់ផ្តើមធ្វើការ ដោយត្រូវអនុវត្តដូចខាងក្រោម៖

- ជ្រើសរើសកាលបរិច្ឆេទចាប់ផ្តើមនិងកាលបរិច្ឆេទបញ្ចប់ នៃថ្ងៃធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ឬថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលនៅក្នុងខែ ឬកាលបរិច្ឆេទលើកទី១និងកាលបរិច្ឆេទលើកទី២នៃការព្យួរការឈប់សម្រាកប្រចាំសប្តាហ៍
- បញ្ជាក់ចំនួនកម្មករនិយោជិតសរុប និងកម្មករនិយោជិតជាស្ត្រី ដែលធ្វើការបន្ថែមម៉ោង ឬធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ឬព្យួរការឈប់សម្រាកប្រចាំសប្តាហ៍

- បញ្ជាក់មូលហេតុនៃការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ឬការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ឬការប្តូរការឈប់សម្រាកប្រចាំសប្តាហ៍
- បញ្ចូលលិខិតបញ្ជាក់ការឯកភាពយ៉ាងតិចពីរភាគបីនៃចំនួនប្រតិភូបុគ្គលិកពេញសិទ្ធិប្រចាំសហគ្រាស គ្រឹះស្ថាន ឬក្នុងករណីមិនទាន់មានប្រតិភូបុគ្គលិក ត្រូវមានការឯកភាពពីកម្មករនិយោជិតយ៉ាងតិច ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកម្មករនិយោជិតសរុបដែលធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ឬធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ឬប្តូរការឈប់សម្រាកប្រចាំសប្តាហ៍ ដោយលិខិតបញ្ជាក់នេះ ត្រូវទាញចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារសម្រាប់ប្រតិភូបុគ្គលិកពេញសិទ្ធិ ឬកម្មករនិយោជិតសរសេរឈ្មោះ និងចុះហត្ថលេខា ឬផ្តិតម្រាមដៃ
- រក្សាទុកឯកសារពាក់ព័ន្ធនឹងការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងការប្តូរការឈប់សម្រាកប្រចាំសប្តាហ៍ សម្រាប់អធិការការងារធ្វើការត្រួតពិនិត្យ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**ប្រការ១៥ ._**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងការផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**ប្រការ១៦ ._**

ការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងការប្តូរការឈប់សម្រាកប្រចាំសប្តាហ៍ ដែលទទួលបានការអនុញ្ញាតនៅមុនកាលបរិច្ឆេទអនុវត្តនៃប្រកាសនេះត្រូវបន្តមានសុពលភាព រហូតដល់កាលបរិច្ឆេទផុតសុពលភាពនៃការអនុញ្ញាតនោះ។

ក្រោយផុតសុពលភាពនៃការអនុញ្ញាតដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងការប្តូរការឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវអនុវត្តស្របតាមបញ្ញត្តិនៃប្រកាសនេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ១៧ ._**

ប្រកាសលេខ ១០ សកបយ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាសថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រកាសលេខ ៨០ សកបយ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ប្រកាសលេខ ១០០ សកបយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ ស្តីពីការប្តូរការសម្រាកប្រចាំសប្តាហ៍ ប្រកាសលេខ ៣៥៧/២១ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីបែបបទ និងនីតិវិធីនៃការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ: ១១៧/២៥ ក.ព/ប្រក.អតភ ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០២៥ ស្តីពី
សៀវភៅបើកប្រាក់

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅបើកប្រាក់

ថ្ងៃ.................... ខែ............. ឆ្នាំ............. ស័ក ព.ស.........
.................... ថ្ងៃទី............ ខែ............ ឆ្នាំ..............

សៀវភៅទី.......

# សៀវភៅបើកប្រាក់

នាមករណ៍សហគ្រាស ៖ ..........................................

សកម្មភាពអាជីវកម្ម ៖ ..........................................

អាសយដ្ឋាន ៖ ផ្ទះលេខ......ផ្លូវ.......ភូមិ..........
ក្រុម.........ឃុំ/សង្កាត់............
ក្រុង/ស្រុក/ខណ្ឌ.....................
រាជធានី/ខេត្ត.........................

QR Code

**នាមករណ៍សហគ្រាសៈ.................................................................**

**បញ្ជីបើកប្រាក់ឈ្នួលប្រចាំខែ........................ ឆ្នាំ.....................**

| ល.រ | គោត្តនាម និងនាម | សញ្ជាតិ | ថ្ងៃខែចូលបម្រើការងារ | មុខងារ | ប្រាក់ឈ្នួលសុទ្ធសាធ | ប្រាក់មុខងារ | ចំនួនថ្ងៃធ្វើការធម្មតា | ប្រាក់តាមចំនួនថ្ងៃធ្វើការធម្មតា | ចំនួនម៉ោងធ្វើការបន្ថែមម៉ោង | ប្រាក់ធ្វើការបន្ថែមម៉ោង | ចំនួនម៉ោងធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ | ប្រាក់ធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ | ចំនួនម៉ោងធ្វើការថ្ងៃបុណ្យ | ប្រាក់ធ្វើការថ្ងៃបុណ្យ | ប្រាក់រង្វាន់ផ្សេងៗ | ចំនួនប្រាក់ទាំងអស់ដែលត្រូវបាន | ប្រាក់ហូតទុក ពន្ធ និងវិភាជន៍ | | ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់ | ប្រាក់បំណាច់អតីតភាពការងារ | | ប្រាក់អត្ថប្រយោជន៍ដែលមិនរាប់បញ្ចូលជាមួយប្រាក់ឈ្នួល | ចំនួនប្រាក់ដែលត្រូវបើក | ហត្ថលេខា |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | | សន្តិសុខសង្គម | ពន្ធ | | រំលឹកឆ្នាំចាស់ | ទូទាត់ក្នុងឆ្នាំ | | | |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |

ថ្ងៃ............. ខែ............... ឆ្នាំ.............
គណនេយ្យករ

ថ្ងៃ............. ខែ............... ឆ្នាំ.............
ម្ចាស់ ឬ នាយកសហគ្រាស គ្រឹះស្ថាន

QR Code